**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)

លេខ......១០៥៤/២១.........គ.វ.ក-១៩

ថ្ងៃ...អង្គារ ១៣រោច...ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី.....១៩..... ខែតុលា ឆ្នាំ២០២១

# សេចក្តីជូនព័ត៌មានបន្ថែម
## ស្តីពី
## ការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋដែលមានវ័យចាស់ ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅកូនដោយទឹកដោះ អ្នកដែលបានព្យាបាលជាសះស្បើយពីជំងឺផ្សេងៗ រួមទាំងជំងឺកូវីដ-១៩ និងអ្នកមានជំងឺប្រចាំកាយ

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមជម្រាបជូនដល់សាធារណជនជ្រាបថា រហូតមកដល់បច្ចុប្បន្ននេះ គ.វ.ក-១៩ សង្កេតឃើញថា មានប្រជាពលរដ្ឋ និងកុមារចាប់ពីអាយុ៦ឆ្នាំឡើង បានស្ម័គ្រចិត្តទៅចាក់វ៉ាក់សាំងកូវីដ-១៩ បានយ៉ាងច្រើន ក្នុងចំណោមនោះក៏មានលោកតា និងលោកយាយ ដែលមានអាយុលើសពី១០០ឆ្នាំ បានមកចាក់វ៉ាក់សាំងកូវីដ-១៩ ប្រកបដោយសុវត្ថិភាពផងដែរ។ ទន្ទឹមគ្នានេះដែរ គ.វ.ក-១៩ សង្កេតឃើញថា នៅមានប្រជាពលរដ្ឋមួយចំនួនតូចមិនទាន់បានស្ម័គ្រចិត្តមកចាក់វ៉ាក់សាំងកូវីដ-១៩ នៅឡើយ ដោយសារមូលហេតុផ្សេងៗ។

គ.វ.ក-១៩ សូមធ្វើការក្រើនរំលឹកជូនសាធារណជនជ្រាបផងដែរថា ចំពោះអ្នកជំងឺកូវីដ-១៩ ដែលបានស្លាប់កន្លងមក ភាគច្រើនជាអ្នកដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូចនេះដើម្បីកាត់បន្ថយសភាពធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ និងកាត់បន្ថយជាអតិបរមា នូវអត្រាស្លាប់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ គ.វ.ក-១៩ សូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ស្ម័គ្រចិត្តទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដោយបងប្អូនអញ្ជើញទៅពិគ្រោះជាមួយគ្រូពេទ្យនៅតាមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដែលស្ថិតនៅជិតទីសំណាក់របស់បងប្អូនឱ្យបានគ្រប់ៗគ្នា។ ចំពោះប្រជាពលរដ្ឋដែលជាក្រុមគោលដៅ និងជាក្រុមដែលប្រឈមទៅនឹងហានិភ័យនៃភាពធ្ងន់ធ្ងរជំងឺកូវីដ-១៩ ដែលអាចស្ម័គ្រចិត្តទៅចាក់វ៉ាក់សាំងកូវីដ-១៩ មានដូចខាងក្រោម ៖

- ប្រជាពលរដ្ឋដែលមានវ័យចាស់
- ស្ត្រីមានផ្ទៃពោះ ឬបំបៅកូនដោយទឹកដោះ
- អ្នកដែលបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ មានរយៈពេលចាប់ពី៤ខែឡើង ឬអ្នកដែលបានជាសះស្បើយពីជំងឺផ្សេងៗទៀត
- អ្នកដែលមានជំងឺប្រចាំកាយ ប៉ុន្តែមានស្ថានភាពនឹងនរ អាចគ្រប់គ្រងបាន

គ.វ.ក-១៩ សូមជម្រាបជូនដល់ ឯកឧត្តម លោកជំទាវ ប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត សូមបន្តធ្វើការណែនាំបន្ថែមដល់ ឯកឧត្តម លោកជំទាវ ប្រធានមន្ទីរសុខាភិបាល រាជធានី-ខេត្ត ត្រូវធ្វើសេចក្តីជូនដំណឹងទៅគ្រប់ទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងអស់ឱ្យផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់ក្រុម



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

គោលដៅ ដែលបានជម្រាបជូនខាងលើឱ្យមានកាពលេូននៅគ្រប់ទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងអស់។ ជាមួយគ្នានេះដែរ គ.វ.ក-១៩ សូមធ្វើការណែនាំដល់ ឯកឧត្តម លោកជំទាវ ប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត អនុវត្តការធ្វើសម្រង់ចំនួនឱ្យបានច្បាស់លាស់នៅតាមផ្ទះ នីមួយៗនូវអ្នកដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ និងមូលហេតុច្បាស់លាស់ ហើយជំរុញការអប់រំដើម្បីឱ្យពួកគាត់យល់ពីសារប្រយោជន៍របស់វ៉ាក់សាំងកូវីដ-១៩ និងសម្រេចចិត្តចាក់ឱ្យបានគ្រប់ៗគ្នាទោះជាមានវ័យចាស់ក៏ដោយ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ និងស្របទៅនឹងបរិបទក្នុងពេលបច្ចុប្បន្ន ដែលកំពុងមានការរាតត្បាតនៅលើពិភពលោក ក៏ដូចជានៅតាមបណ្តាប្រទេសនីមួយៗពីវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីៗ ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទដែលតា ដែលកំពុងចរាចរយ៉ាងសកម្មនៅប្រទេសជាច្រើន ក៏ដូចជាប្រទេសកម្ពុជាផងដែរនោះ គ.វ.ក-១៩ សូមអំពាវនាវដល់លោកអ៊ំ ពូ មីង ពុក ម៉ែ បងប្អូន ព្រមទាំងក្មួយៗ ដែលមានអាយុចាប់ពី៦ឆ្នាំឡើងទាំងអស់ដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ សូមស្រាកស្រាន់ស្ម័គ្រចិត្តទៅចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានគ្រប់គ្នា ដើម្បីបង្កើតភាពស៊ាំក្នុងខ្លួន និងភាពស៊ាំក្នុងសហគមន៍ សម្រាប់ទប់ទល់ពីការវាយលុកនៃវីរុសកូវីដ-១៩ សំដៅកាត់បន្ថយភាពធ្ងន់ធ្ងរនៃអ្នកជំងឺកូវីដ-១៩ និងកាត់បន្ថយនូវអត្រាសម្រាកពេទ្យ ក៏ដូចជាកាត់បន្ថយជាអតិបរមានូវអត្រាស្លាប់ដែលបណ្តាលមកពីជំងឺកូវីដ-១៩។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ /លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០៨៩ ៩៨០ ៦៦៦ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)**

**វេជ្ជ. ឱ វណ្ណឌីន**